# យពាន់ឧបសគ្គនៃចំណាកស្រុក

## សម្លេងរបស់អ្នកចំណាកស្រុកទៅប្រទេសថៃ



# រយៈពាន់ឧបសគ្គនៃចំណាកស្រុក

## សម្លេងរបស់អ្នកចំណាកស្រុកទៅប្រទេសថៃ

រចនារូបភាពដោយ Nicola Streeten

បោះពុម្ពដោយ សកលវិទ្យាល័យសាសស៊ិច ប្រទេសអង់គ្លេស
បោះពុម្ពលើកទី១ ខែកក្កដា ឆ្នាំ២០១៦

គ្រប់ខ្លឹមសារនៃការសៀវភៅនេះគឺត្រូវបានរក្សាសិទ្ធ
Copyright © University of Sussex and the artist

សៀវភៅនេះអាចនឹងត្រូវយកមកប្រើប្រាស់ឡើងវិញឬបោះពុម្ពសារជាថ្មី សំរាប់តែក្នុងគោលបំណងមិនមែនដើម្បីធ្វើពាណិជ្ជកម្ម តែត្រូវមានការទទួលស្គាល់ចំពោះសកលវិទ្យាល័យសាសស៊ិច និងវិចិត្រករ Nicola Streeten ។

សៀវភៅនេះត្រូវបានបោះពុម្ពដោយក្រុមកម្មវិធីស្រាវជ្រាវចំណាកស្រុកដើម្បីគេចចេញពីភាពក្រីក្រ ដែលទទួលបានការឧបត្ថម្ភថវិកាដោយនាយកដ្ឋានសំរាប់ការអភិវឌ្ឍអន្តរជាតិនៃប្រទេសអង់គ្លេស (DFID) ។ DFID គាំទ្រគោលនយោបាយ កម្មវិធី និងគំរោងដើម្បីលើកកំពស់ការកាត់បន្ថយភាពក្រីក្រជាលក្ខណៈសកល។ DFID ផ្តល់ថវិកាសំរាប់រៀបចំការស្រាវជ្រាវនេះ ដែលជាចំណែកមួយនៃគោលដៅរបស់ DFID តែទោះជាយ៉ាងណាក្តីទស្សនៈយោបល់ដែលបង្ហាញក្នុងឯកសារនេះមិនឆ្លុះបញ្ចាំងគោលនយោបាយរបស់រដ្ឋាភិបាលប្រទេសអង់គ្លេសឡើយ។

ISBN: 978-0-904760-00-2

migratingoutofpoverty.dfid.gov.uk/publications/multimedia

UNIVERSITY OF SUSSEX    Migrating out of Poverty    UKaid from the British people

## សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកចំណាកស្រុកទាំងអស់ និងក្រុមគ្រួសាររបស់ពួកគាត់ដែលបានលះបង់ពេលវេលាដើម្បី ចូលរួមចែករំលែកបទពិសោធន៍នៃការធ្វើចំណាកស្រុក និងធ្វើការនៅប្រទេសថៃ។ ឈ្មោះរបស់ពួកគាត់ត្រូវបានផ្លាស់ប្តូរដើម្បីរក្សាអនាមិកភាព។ ពួកយើងក៏សូមថ្លែងអំណរគុណផង ដែរចំពោះអ្នកចុះសំភាសន៍ដែលបានជួយសំរបសំរួលក្នុងដំណើរការសំភាសន៍ដែលអាចឲ្យអ្នកចូលរួមអាចរៀបរាប់រឿងរ៉ាវរបស់ពួកគេបានយ៉ាងមានប្រសិទ្ធភាព។ ពួកគេទាំងនោះរួមមាន លោកស្រី **ចេប ម៉ាលីបុផ្ផា** លោក **អៀ អ៊ីល** និងលោកស្រី **ហាក់ សុចន្ទី**។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោក **Alan Winters** លោក **Allison Baldasare** លោកស្រី **Dorte Thorsen, Julie Litchfield, Priya Deshingkar,** និងលោកស្រី **ហាក់ សុចន្ទី** សំរាប់ការផ្តល់យោបល់ទៅលើសេចក្តីព្រាងនៃសៀវភៅនេះ។


ប្រទេសថៃ
ទីក្រុងបាងកក
ប្រទេសកម្ពុជា
សូមស្វាគមន៍ចំពោះការមកដល់ប្រទេសថៃ
សូមបើកគំរបឡាន




ចេញដំណើរបាន






# នៅការដ្ឋានសំណង់ទីក្រុងបាងកក



មួយអាទិត្យក្រោយមក






៤អាទិត្យក្រោយមក


ខ្ញុំនឹកកូនៗណាស់។ បងគិតថាពួកវាសុខធម្មតាទេជាមួយម៉ែមែនអត់?
ខ្ញុំគិតថាម៉ែរបស់អូនឯងជាមនុស្សល្អ ហើយយើងខំធ្វើការនេះគឺដើម្បីឲ្យជីវភាពរបស់ពួកយើងបានល្អប្រសើរជាងមុន។ តោះ យើងសំរាកតិចទៅហី?




បងឯងគិតថាពួកយើងនឹងទទួលប្រាក់ឈ្នួលនៅថ្ងៃស្អែកដែរអត់?
ពិតជាបាន...... ថៅកែចង់បំបែកក្រុមយើង ហើយយកប្អូនស្រីជីដូនមួយទៅធ្វើការនៅការដ្ឋានមួយទៀត អាទិត្យក្រោយ។
ទេ! យើងមិនអាចឲ្យគាត់ធ្វើចឹងបានទេ។ ប្អូនស្រីជីដូនមួយនៅលីវផង ចឹងយើងត្រូវជួយការពារនាង....... បងឯងមានប្រាប់ថៅកែ ថាចឹងអត់?
ប្រាប់ ហើយបងក៏បានប្រាប់បងឡុឲ្យនិយាយជាមួយថៅកែដែរ
បងមានខ្ចីលុយពីមេការសំរាប់ទិញម្ហូបទេ?
បងបានខ្ចី

៦អាទិត្យក្រោយមកនៅផ្សារ នៅក្នុងប្រទេសកម្ពុជា







ខ្ញុំអត់មានលុយទេ ខ្ញុំទើបតែឲ្យវាផឹកថ្នាំខ្មែរខ្លះ តែវាដូចជាមិនធូរស្រាលសោះ
មីង ទៅខ្ចីលុយពីអ្នកចងការប្រាក់ទៅ! ក្មេងតូចនេះត្រូវតែយកវាទៅជួប គ្រូពេទ្យទើបបាន.......
ម៉េចក៏មីងមិនដាក់ពាក្យសុំខ្ចីលុយពីអង្គការទៅ...... .. ប្រាប់គេថាមីងចង់ទិញមាន់ មកចិញ្ចឹមថែមទៀត...... ឬពង្រីកមុខរបរ។ បន្ទាប់មកយកលុយហ្នឹងទៅសងអ្នកចងការប្រាក់ទៅ ធ្វើចឹងវាអស់ការប្រាក់តិចជាង។
ចឹងតើខ្ញុំគួរធ្វើម៉េចទៅបើគេចុះមកពិនិត្យដល់ផ្ទះ?
បង្ហាញមាន់ដែលមីងបានចិញ្ចឹមស្រាប់ហ្នឹងទៅគេទៅ ហើយប្រាប់គេថាមីងចង់ចិញ្ចឹមថែមទៀតដើម្បីទុកលក់តាមផ្សារ...... ឆាប់ទៅទិញថ្នាំឲ្យចៅមីងទៅ!


វាដូចជាមិនត្រូវសោះ សូម្បីតែ ក្មួយស្រីខ្ញុំដែលនៅលីវក៏ធ្វើការនៅថៃដែរ ហើយភ្លេចខ្លួន វាធ្វើបាន១០ឆ្នាំហើយ!
មែនហើយ តែក្មួយមីងទទួលបានការការពារបានល្អ ហើយវានៅធ្វើការជាមួយកូនមីងដែរ។
ហ៊ឺ! និយាយចឹងខ្ញុំបារម្ភពីការខ្ចីលុយពីអ្នកចងការប្រាក់ណាស់។ ពេលសងវិញទាំងការទាំងដើម វាច្រើនណាស់
បើសិនបើកូនខ្ញុំមិនផ្ញើលុយមកទេ ខ្ញុំមិនអាចយកលុយដែលបានពីការលក់បន្លែបន្តិចបន្តួចនេះទៅសងគេរួចទេ។
អ្នកចងការប្រាក់នឹងដកហូតយកដីផ្ទះរបស់ខ្ញុំ ចឹងខ្ញុំនឹងគ្មាននៅសេសសល់អ្វីទៀតទេ។
ចឹងមីងគួរតែខ្ចីលុយពីអង្គការទៅ


ថ្ងៃបន្ទាប់....
ម៉ែ ម៉ែ! តើមានរឿងអ្វីកើតឡើងហ្នឹង? ម៉ែមានរឿងអី?
គឺអាបា ...... អាបាវាឈឺ ឲ្យម៉ែសុំទោស ម៉ែឲ្យថ្នាំពេទ្យវាលេបហើយ .....ឲ្យម៉ែសុំទោស
តើវាឈឺអីម៉ែ?
វាគ្រុនក្ដៅ។ ពេទ្យនិយាយថាវាក្ដៅខ្លួនបណ្ដាលមកពីវីរុស ហើយវានឹងធូរស្បើយឡើងវិញ តែម៉ែចេះតែខ្លាច។

ថ្ងៃបន្ទាប់....


បងឡូ បងឯងអាចផ្ញើលុយខ្លះឲ្យម៉ែនៅថ្ងៃស្អែកបានទេ? .... ប្រាក់ខែ យើងមិនជាច្រើនប៉ុន្មានទេមែនទេ បន្ទាប់ពីថៅកែបានកាត់ប្រាក់ ពីការជួលបន្ទប់។
មែនហើយ ...... តែគាត់បានជួរចិត្តវិញនៅពេលដែលប្រគែកមិនព្រមទៅធ្វើការឆ្ងាយពីប្អូនពីជូនមួយ
តែយ៉ាងហោចណាស់ពេលទទួលបានលុយហ្នឹងម៉ែអាចទិញថ្នាំពេទ្យឲ្យអាបាបាន ហើយយើងអាចសងបំណុលបានឆាប់
ថៅកែមួយនេះដូចជាមិនអីទេ គាត់ធ្លាប់បានជួយការពារប្អូនស្រីពីជូនមួយពេលដែលប៉ូលីសចូលឆែកនៅការដ្ឋាន។
អូហ៎ឡូ វាជារឿងគ្រោះថ្នាក់ណាស់
វាជារឿងប្រថុយប្រថានមែន តែវាមិនដូចជំនាន់ ប៉ុលពត ដូចដែលម៉ែធ្លាប់បានពោលនោះទេ។ពួកយើងសំរេចចិត្តមកទីនេះគឺដើម្បីធ្វើការ ដើម្បីឲ្យបានជីវភាពធូរធារ។


ពួកយើងឮថាប៉ូលីសថៃបានមកដល់ការដ្ឋាន ហើយថៅកែបានប្រាប់ឲ្យយើងរត់ពួនសិន។


ពួកយើងពួនរហូតដល់មេឃងងឹត.
ឯងមិនគិតថាពួកយើងគួរតែរត់ឲ្យឆ្ងាយឲ្យដល់ភូមិរបស់យើងតែម្តងទេហេ? ខ្ញុំខ្លាចណាស់.....
តែថៅកែនៅមិនទាន់បើកប្រាក់ឲ្យយើង នៅឡើយទេ ពួកយើងមិនទាន់ទទួលបានប្រាក់ឈ្នួលអស់រយៈពេល៣អាទិត្យហើយ។
ថៅកែប្រាប់ឲ្យយើងត្រឡប់ទៅវិញពេលមេឃងងឹត ព្រោះថាគាត់បាននិយាយជាមួយ ប៉ូលិសហើយ។
ចឹងមានតែគាត់បង់លុយឲ្យប៉ូលីសដើម្បីឲ្យយើងអាចរត់គេចបានទេដឹង?
ហ៊ឹះគាត់ធ្វើចឹងហើយបន្ទាប់មកគាត់ប្រាកដជាកាត់លុយចេញពីប្រាក់ឈ្នួលដែលពួកយើងត្រូវទទួលបានហើយ។
ខ្ញុំបានឮគេនិយាយថាថៅកែហ្នឹងបានគេទៅ ប៉ូលីសឲ្យមកចាប់យើង គាត់ធ្វើចឹងដើម្បីឲ្យ យើងរត់គេចរួចហើយគាត់មានលេសមិនបើកប្រាក់ឈ្នួលឲ្យពួកយើង
ពួកយើងបានត្រឡប់មកការដ្ឋានវិញពេលពាក់កណ្តាលអធ្រាត




ម៉ែខ្លាចខ្លាំងណាស់កូន! នៅឯណោះពួកយើងឮពាក្យចចាមអារ៉ាមអំពីអ្វីដែលអាចកើតឡើងនៅពេលដែលពួកឯងត្រូវបានគេចាប់
សូមប្រយ័ត្នប្រយែងណា កុំទៅណាតែម្នាក់ឯង! កូនឯងត្រូវតែត្រឡប់មកផ្ទះវិញមកកូន! ម៉ែខ្លាចណាស់។ កូនៗរបស់ឯងវាត្រូវការឯង! អ្វីដែលបានកើតឡើងនេះធ្វើឲ្យម៉ែនឹកឃើញអំពីជំនាន់ខ្មែរក្រហម គឺកូនៗបានព្រាត់ប្រាស់ពីឪពុកម្តាយខ្លួន។ បើយើងមិនអាចសងបំណុលគេបានទេ យើងនៅតែអាចហូបបាយជាមួយអំបិលដែរ តែកូនៗរបស់ឯងពួកវាមិនអាចបាត់បង់ឯងទេ!







នៅព្រឹកព្រលឹមថ្ងៃបន្ទាប់




អ្នកមៅការនិយាយថាស្អែកមានទាហានមកទីនេះ។ ពួកគេនឹងបង្ក្រាបនិងចាប់ខ្លួនអ្នកដែលមកធ្វើការអត់មានលិខិតឆ្លងដែន។
ខ្ញុំគិតថាពួកយើងត្រូវតែចាកចេញពីទីនេះ
ប្អូនជីដូនមួយ តើថៅកែឯងមិនជួយការពារឯងទេហេ?
អាទិត្យមុន គាត់និយាយថាបើការដ្ឋានហ្នឹង ត្រូវបានគេចុះឆែក គាត់នឹងធានាថាពួកគេមិនអាចចាប់ខ្លួនខ្ញុំទេ
ចឹងល្អហើយ តែពួកយើងគួរតែនៅជុំគ្នា ទៅតាមតែអ្នកដែលខ្ញុំបានប្រាប់ទៅបានហើយ
ហើយអ្នកទាំងអស់គ្នាគួរតែលាក់លុយតាមខ្លួនជានិច្ចគ្រប់ពេលទាំងអស់




ពុទ្ធោអើយ! ទាហានមកហើយ!
រត់!!!
នៅពេលស្ងាត់បន្តិចចាំពួកយើងនាំគ្នាទៅជិះរថភ្លើងដូចដែលអាឡុបានប្រាប់
ចុះអាឡុ នៅណា?
ខ្ញុំបានឃើញប៉ូលីសចាប់គាត់បាត់ហើយ
ឱព្រះអើយ! តើវានឹងមានរឿងអ្វីខ្លះកើតឡើង ចំពោះគាត់?
វាប្រាកដជាមិនអីទេ ព្រោះវាមានលុយខ្លះនៅជាប់ខ្លួន ហើយវាអាចនិយាយភាសាថៃបានខ្លះៗដែរ
តើយើងអាចយកឥវ៉ាន់របស់យើងមុនគេបានទេ?
ខ្ញុំគិតថាយើងមិនគួរប្រថុយធ្វើចឹងទេ


ពួកយើងត្រូវប្រយ័ត្នលាក់លុយ យើងឲ្យជិតទុកក្នុងអាវទ្រនាប់ខ្លះ ទៅ ក្នុងហោប៉ៅខ្លះទៅ។ ទុកក្នុងកាបូប តែចំនួនតិចតួចបានហើយ
...ពេលដែលពួកឯងឡើងលើរថភ្លើង វានឹងមានប្រុសៗមកប្រមូលលុយ ពួកគេ មើលទៅស្លៀកពាក់ដូចប៉ូលីសចឹង តែពួកវា មិនមែនទេ គ្រាន់តែជាអ្នកឆ្លៀតឱកាសតែប៉ុណ្ណឹងៗ
ពេលជួបពួកហ្នឹង លើកដៃសំពះគេទៅ... គឺសំពះបែបនេះ.....
ហើយនិយាយថាឯងគ្មានលុយទេ។ ឯងបង់លុយឲ្យតែថ្លៃរថភ្លើងពេល ឡើងជិះហ្នឹងបានហើយ តែប៉ុណ្ណឹងឯង។
ខ្ញុំបានជួលឡានឲ្យមកចាំទទួលនៅព្រំដែន។ យើងត្រូវតែចេញដំណើរឥឡូវនេះ ។ វាមិនស្រួលជាងាយស្រួលប៉ុន្មានទេ តែវាមានសុវត្ថិភាព




វាដូចជាមនុស្ស ច្រើនខ្លាំងណាស់ មែនទេ?
មែនហើយ ជាក់ស្តែងមានផ្សារធំមួយ ដែលមនុស្សភាគច្រើនចូលចិត្ត ទៅជារៀងរាល់ថ្ងៃអង្គារ៍
ឡូយមែនៗ ស្តាប់មើលទៅ ដូចជាកន្លែងល្អ សំរាប់ថតរូប
សូមបង់ថ្លៃធ្វើដំណើរ
ពួកយើងអត់មានលុយទេ


ពួកយើងបានធ្វើដំណើរតាមឡានភីកអាប់តាមផ្លូវសំងាត់ដែលអាចគេចពីប៉ូលីសបាន។
វាមិនស្រួលទេ តែពួកយើងបានមកដល់ព្រំដែន ប្រទេសកម្ពុជាដោយសុវត្ថិភាព
ហើយយើងអាចបន្តដំណើរភ្លាមៗទៅដល់ភូមិរបស់ពួកយើង។




ពេលដែលកូនៗបានត្រឡប់មកដល់ផ្ទះវិញដោយសុវត្ថិភាព គឺដូចបានដកបន្លាចេញពីទ្រូងខ្ញុំចឹង។


ប្អូនជីដូនមួយខ្ញុំបានឮថាថៅកែបានស្នើសុំបានប័ណ្ណអនុញ្ញាតិការងារសំរាប់ឯងហើយមែនទេ?
ចា៎ តែវាថ្លៃ។ គាត់នឹងកាត់ចេញពីប្រាក់ឈ្នួល របស់ខ្ញុំ។ គាត់និយាយថាបើអ្នកទាំងបីចង់ត្រឡប់ទៅវិញ គាត់នឹងជួយរៀបចំឲ្យ ធ្វើលិខិតឆ្លងដែននិងប័ណ្ណអនុញ្ញាតិការងារ។
អ្នកនៅជិតខាងយើងប្រាប់ថាខ្ញុំគួរតែសុំខ្ចីលុយពីអង្គការ ដើម្បីយកទៅសងអ្នកចងការប្រាក់
ហើយចឹងយើងអាចប្រើលុយដែលនៅសល់សំរាប់ធ្វើដំណើរត្រឡប់ទៅវិញ
ហើយចំណាយសំរាប់ធ្វើលិខិតឆ្លងដែននិង រៀបចំឯកសារផ្សេងទៀតដែលអាចធ្វើការបានដោយស្របច្បាប់
មិត្តភ័ក្រ្តរបស់ខ្ញុំបានលក់ដីដើម្បីចំណាយ សំរាប់ធ្វើលិខិតឆ្លងដែន ដែលអាចឲ្យគាត់ចំណាកស្រុកទៅធ្វើការ នៅថៃបានដោយមិនភ័យនឹងការតាមចាប់
ប៉ុន្តែ គាត់ត្រូវបានគេបោកប្រាស់ ហើយក្រោយមកគាត់បានគេចទៅធ្វើការមិនស្របច្បាប់វិញ




ហើយបើរឿងហ្នឹងវាកើតឡើងចឹងមែន ហើយយើងត្រូវបានគេបង្ខំឲ្យត្រឡប់មកវិញ តើយើងមានលុយឯណាយកទៅសងបំណុលដែលថែខ្ចី?
ខ្ញុំចង់ត្រឡប់ទៅធ្វើការវិញតែពេលណាដែលយើងមានឯកសារស្របច្បាប់គ្រប់គ្រាន់ទេ។ តែបើយើងដាក់ពាក្យសុំធ្វើលិខិតឆ្លងដែននៅស្រុកខ្មែរ វាចំណាយពេលយូរ។
....តែបើយើងធ្វើនៅស្រុកថៃវិញ ថៅកែនឹងចេញលុយឲ្យសិន ហើយបានគាត់កាត់ចេញពីប្រាក់ឈ្នួលរបស់យើង។ ខ្ញុំគិតថាធ្វើចឹងវាស្រួលជាង
តែ ប្រហែលជាលុយហ្នឹងយើងទុកសំរាប់ចំណាយទៅលើការធ្វើស្រែចំការវិញ ដែលអាចឲ្យយើងមានជីវភាពប្រសើរក្នុងគ្រួសាររបស់យើងនៅទីនេះ។
រដ្ឋាភិបាលខ្មែរគួរតែយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ហើយជួយសំរួលឲ្យពួកយើងអាចធ្វើចំណាកស្រុកទៅបានដោយគ្មានបញ្ហានិងការបារម្ភ

## ព័ត៌មានអំពីគំរោង

ក្នុងខែឧសភា ឆ្នាំ២០១៤ យោធាថៃបានធ្វើរដ្ឋប្រហារនិង បានទំលាក់រដ្ឋាភិបាលស៊ីវិល។ ក្នុងខែមិថុនាឆ្នាំដដែលរដ្ឋាភិបាលថ្មីបានចេញសេចក្តីប្រកាសព័ត៌មានដែលព្រមានដល់កម្មករចំណាកស្រុកដែលគ្មានឯកសារត្រឹមត្រូវដែលថាពួកគេគួរតែចាកចេញពីប្រទេសថៃ បើមិនដូច្នេះទេពួកគេនឹងប្រឈមមុខនឹងការចាប់ខ្លួននិងបញ្ជូនចេញពីប្រទេសថៃ។ ក្នុងរយៈពេលប្រហែលជា២សប្តាហ៍ ក្នុងខែមិថុនា ឆ្នាំ ២០១៤ កម្មករចំណាកស្រុកខុសច្បាប់ប្រហែលជាជិត ២២០,០០០នាក់ ត្រូវបានបញ្ជូនចេញពីប្រទេសថៃ។

ខ្ញុំធ្លាប់បានធ្វើការនៅតាមភូមិដែលជិតព្រំដែនកម្ពុជា-ថៃ តាំងពីខែកញ្ញាឆ្នាំ២០១៣។ ខ្ញុំមានការចាប់អារម្មណ៍ដោយសង្កេតឃើញថាមានគ្រួសារជាច្រើនដែលក្នុងនោះមានសមាជិកគ្រួសារម្នាក់ ឬ លើសពីនេះបានធ្វើចំណាកស្រុកស្វែងរកការងារធ្វើដើម្បីផ្គត់ផ្គង់គ្រួសារក្នុងភូមិ។ ដោយបានពិភាក្សាអំពីចំណាប់អារម្មណ៍នេះជាមួយសហការីនៅប្រទេសកម្ពុជានិងនៅសកលវិទ្យាល័យសាសស៊ិច សំណើរសុំស្រាវជ្រាវមួយត្រូវបានបង្កើតឡើងដែលមានគោលបំណងស្វែងយល់អំពីហេតុផលនៃការធ្វើចំណាកស្រុកនិងភាពពាក់ព័ន្ធរបស់វានៅក្នុងគ្រួសារ និងការរួមចំណែកនៃការធ្វើចំណាកស្រុកដើម្បីជីវភាពរស់នៅ។ ពួកយើងចាប់អារម្មណ៍ជាពិសេសទៅលើផលប៉ះពាល់នៃការត្រឡប់មកវិញដោយបង្ខំឬមិនស្ម័គ្រចិត្តរបស់ជនចំណាកស្រុកនិងគ្រួសាររបស់ពួកគេ។

សៀវភៅរឿងនេះតំណាងឲ្យវិធីសាស្ត្រជាច្រើនដែលពួកយើងអាចចែករំលែករឿងរ៉ាវផ្សេងៗរបស់ជនចំណាកស្រុក និងគ្រួសាររបស់ពួកគេជាមួយអ្នកអានជាទូទៅក្រៅពីមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវដែរ។ យើងសង្ឃឹមថាសៀវភៅរឿងនេះនឹងរួមចំណែកដល់ការយល់ដឹងរបស់អ្នកអានអំពីបញ្ហាប្រឈមនិងឱកាសដែលជនចំណាកស្រុកជួបប្រទះ។ យើងសង្ឃឹមថារឿងនេះក៏នឹងរួមចំណែកដល់ការពិភាក្សា និងលើកកំពស់ការយល់ដឹងអំពីបញ្ហាចំណាកស្រុកនេះក្នុងចំណោមស្ថាប័ន រដ្ឋាភិបាល អង្គការសង្គមស៊ីវិលដែលធ្វើការជាមួយជនចំណាកស្រុក និងក្នុងចំណោមសាធារណជនផ្សេង។

ការស្រាវជ្រាវនេះត្រូវបានគាំទ្រថវិកាដោយកម្មវិធីស្រាវជ្រាវស្តីពីការធ្វើចំណាកស្រុកដើម្បីចាកចេញពីភាពក្រីក្រ (Migrating out of Poverty Research Programme Consortium) របស់សកលវិទ្យាល័យ សាសស៊ិច ។

migratingoutofpoverty.dfid.gov.uk □
លទ្ធផលរកឃើញចេញពីការស្រាវជ្រាវនេះនឹងត្រូវបោះពុម្ពផ្សាយនៅឆ្នាំ ២០១៧។

លោក រ៉ូបឺត នីវ៉ែក ខែកក្កដា ២០១៦
នាយកប្រតិបត្តិនៃកម្មវិធីការធ្វើចំណាកស្រុកដើម្បីចាកចេញពីភាពក្រីក្រ នៃសាកលវិទ្យាល័យសាសស៊ិច
អ្នកស្រាវជ្រាវជាន់ខ្ពស់នៃសាកលវិទ្យាល័យម៉ែលប៊ើន ប្រទេសអូស្ត្រាលី